**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៤៤៤១ **អយក. ប,ល**

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០១៥*

## ជម្រាបជូន
## លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់រាជធានី ខេត្ត

**កម្មវត្ថុៈ** ពង្រឹងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងថ្នាក់គួប ។

**យោងៈ** - អនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀន ក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

- សារាចរលេខ ០២ អយក.សរាច ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ៣០៩ អនក្រ.បក ស្តីពីការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀន ក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជម្រាបជូនលោក លោកស្រី ប្រធានថាៈ នៅឆ្នាំសិក្សា ២០១៤-២០១៥ ក្រសួងបានដាក់ឱ្យអនុវត្តសាកល្បងនូវ សេចក្តីណែនាំលេខ ៣៣ អយក.សណន ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៤ ស្តីពីនិយាមប្រើប្រាស់បុគ្គលិក នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តស្វាយរៀង និងខេត្តមណ្ឌលគិរី ។

សម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦ ក្រសួងនឹងបន្តអនុវត្តនិយាមថ្មីសម្រាប់រាជធានី ខេត្ត ដែលបានដាក់ឱ្យអនុវត្តកន្លងមក លើកលែងតែ ខេត្តបាត់ដំបង និងខេត្តមិនស្ថិតជាខេត្តគោលដៅសាកល្បងនិយាមថ្មី ត្រូវអនុវត្តតាមនិយាមលេខ ២៥៦ អយក.សណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ស្តីពីការប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ ។ ដើម្បីឱ្យដំណើរការគ្រប់គ្រង និងចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ទទួលបានប្រសិទ្ធភាពខ្ពស់សម្រាប់ឆ្នាំសិក្សាថ្មី ក្រសួងសូមធ្វើការណែនាំដូចខាងក្រោមៈ

### ១.ការរៀបចំនិយាមសិស្ស ថ្នាក់

- សម្រាប់រាជធានី ខេត្តអនុវត្តនិយាមលេខ ៣៣ អយក.សណន ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៤ ចំនួនសិស្សថ្នាក់ទី១ ទី២ និងទី៣ លើសពី ៥០ នាក់ ទើបអនុញ្ញាតឱ្យបំបែកជាពីរថ្នាក់ និងចំនួនសិស្សថ្នាក់ទី៤ ទី៥ និងទី៦ លើសពី ៥៥ នាក់ ទើបអនុញ្ញាតឱ្យបំបែកជាពីរថ្នាក់

- សម្រាប់ខេត្ត អនុវត្តនិយាមលេខ ២៥៦ អយក.សណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ចំនួនសិស្ស ថ្នាក់ទី១ ដល់ ថ្នាក់ទី៦ លើសពី ៦០ នាក់ ទើបអនុញ្ញាតឱ្យបំបែកជាពីរថ្នាក់ ។

២.ការរៀបចំសេវាបង្រៀន និងការប្រើប្រាស់គ្រូជាប់កិច្ចសន្យា ថ្នាក់ពីរពេល និងថ្នាក់គួប

- រៀបចំឱ្យមានគ្រូបង្រៀននៅតាមកម្រិតថ្នាក់នីមួយៗ ឱ្យអស់លទ្ធភាពជាមុនសិនទើប រៀបចំបុគ្គលិកឱ្យបម្រើការងាររដ្ឋបាលនៅទីចាត់ការ

- ការរៀបចំថ្នាក់បង្រៀនពីរថ្នាក់ពីរពេលត្រូវផ្តល់ឱ្យគ្រូបង្រៀនជាមុន អស់លទ្ធភាពទើបរៀបចំឱ្យបុគ្គលិកបម្រើការងារនៅទីចាត់ការ ឬ នាយក ឬ នាយករង តាមក្រោយ

- មិនអនុញ្ញាតឱ្យរៀបចំបង្រៀនពីរថ្នាក់ពីរពេល ចំពោះគ្រឹះស្ថានបឋមសិក្សាណា ដែលមានចំនួនសិស្សតិច មិនស្របតាមនិយាមកំណត់ ហើយស្ថិតក្នុងស្ថានភាពដែលតម្រូវឱ្យបង្រៀនថ្នាក់គួប

- ត្រូវរៀបចំឱ្យមានថ្នាក់គួបពីរកម្រិត ឬ គួបបីកម្រិត ទៅតាមស្ថានភាពចំនួនសិស្សពិតប្រាកដ ដែលអាចរៀបចំជាថ្នាក់គួបបាន

- ចំនួនសិស្សថ្នាក់គួបពីរកម្រិត ឬ ថ្នាក់គួបបីកម្រិត ត្រូវស្របតាមនិយាម បើអាចធ្វើទៅបាន ឬ អាចលើសបន្តិចបន្តួច ទៅតាមស្ថានភាពជាក់ស្តែង

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំសេចក្តីប្រកាសស្តីពីការជ្រើសរើស គ្រូបង្រៀនជាប់កិច្ចសន្យា ដោយបញ្ជាក់ពីទីតាំងដែលត្រូវបង្រៀន និងចំនួនជ្រើសរើស

- ការជ្រើសរើសគ្រូជាប់កិច្ចសន្យាត្រូវធ្វើតេស្តវាស់ស្ទង់សមត្ថភាពច្បាស់លាស់ និងត្រូវមានការចូលរួមសម្រេចពីក្រុមប្រឹក្សាឃុំ និងសហគមន៍

- គ្រូបង្រៀនជាប់កិច្ចសន្យាដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ ឬ បានរៀនចប់ថ្នាក់ទី១២ លើកលែងតែគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌដែលចូលនិវត្តន៍ និងគ្រូបង្រៀនជាប់កិច្ចសន្យា ដែលបានបង្រៀនក្នុងវិស័យអប់រំ ចាប់ពី ០៤ ឆ្នាំឡើងទៅ

- ការប្រើប្រាស់គ្រូជាប់កិច្ចសន្យាត្រូវគោរពទៅតាមចំនួនដែលក្រសួងផ្តល់ឱ្យ

- ការខ្ចីគ្រូបង្រៀនពីសាលារៀនមួយទៅបង្រៀននៅសាលារៀនមួយផ្សេងទៀត ត្រូវគិតពីចម្ងាយផ្លូវធ្វើដំណើររបស់គ្រូបង្រៀននោះឱ្យបានច្បាស់លាស់ និងអាចទៅបំពេញការងារបង្រៀនដោយមានភាពងាយស្រួល

- រៀបចំឱ្យមានផែនការច្បាស់លាស់ក្នុងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងថ្នាក់គួប មុនពេលបើកបវេសនកាល

- មិនអនុញ្ញាតឱ្យជួលអ្នកផ្សេងបង្រៀនជំនួសឈ្មោះរបស់ខ្លួន ក្នុងការបង្រៀនពីរថ្នាក់ពីពេល និងថ្នាក់កិច្ចសន្យា

- ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យចំនួនសិស្សថ្នាក់ឱ្យបានច្បាស់ និងតាមភាពជាក់ស្តែង ទើបអនុញ្ញាតឱ្យគ្រឹះស្ថានបឋមសិក្សាប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរពេល និងថ្នាក់គួប

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពិនិត្យដោយយកចិត្តទុកដាក់ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំសេវាបង្រៀន និងការអនុញ្ញាតឲ្យគ្រឹះស្ថានបឋមសិក្សាប្រើប្រាស់ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងថ្នាក់គួប ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមលោក លោកស្រី មេត្តាផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវ តាមការគួរ ។

សូម លោក លោកស្រីប្រធាន ទទួលនូវការរាប់អានពីខ្ញុំ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**

- ក្រសួងមុខងារសាធារណ:
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន

"ដើម្បីជ្រាបជាពត៌មាន"

- កាលប្បវត្តិ ឯកសារ នា.បុគ្គលិក

**ខេត្តកណ្ដាល**
មន្ទីរអប់រំ យុវជន និងកីឡា
លេខ ០៩៤ មអយក.ចល

**ចតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមក**
ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
កណ្ដាល ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៥
**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

អ៊ុង_តុលា